**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ..05/04..កបធ.ស.ជ.ណ.

រាជធានីភ្នំពេញ, ថ្ងៃទី...០៥.... ខែ..មេសា.. ឆ្នាំ..២០០៤..

## ជំរាបជូន

## ឯកឧត្តម លោកជំទាវ ជាតំណាងរាស្ត្រចំនួន ១៨ រូប

**កម្មវត្ថុ** : សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយនូវមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ

**យោង** : លិខិតចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៤ របស់ឯកឧត្តម លោកជំទាវ

ក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យរបស់ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើនេះហើយ ប៉ុន្តែបានកត់សំគាល់ឃើញថា មិនមែនជាពាក្យសុំបកស្រាយសុទ្ធសាធទេ គឺមាន ការចោទប្រកាន់មកលើក្រុមប្រឹក្សាធម្មនុញ្ញថែមទៀតផង ដោយមានសរសេរថា " *យើងខ្ញុំសូមរៀបរាយនូវ សំណួរនេះឡើងវិញ ដោយសង្ឃឹមថាលើកនេះ ក្រុមប្រឹក្សាធម្មនុញ្ញនឹងមិនយកមូលហេតុណាទៀត ដើម្បី មិនធ្វើការបកស្រាយមាត្រានៃរដ្ឋធម្មនុញ្ញ ...* " ។

ការចោទប្រកាន់បែបនេះ ជាការប្រមាថដល់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នច្បាប់កំពូល មួយ ។ ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចទទួលយកការចោទប្រកាន់នេះបានទេ ពីព្រោះក្រុមប្រឹក្សាធម្មនុញ្ញ មិនដែលបានយកមូលហេតុមិនត្រឹមត្រូវណាមួយ មកបដិសេធពាក្យសុំបកស្រាយរដ្ឋធម្មនុញ្ញរបស់ឯកឧត្តម លោកជំទាវ ម្តងណាឡើយ ។ ការខុសទម្រង់ច្បាប់ គឺជាការខុសច្បាប់ ដែលធ្វើឱ្យរាំងស្ទះដល់ការទទួល ពិនិត្យនូវបញ្ហាដែលឯកឧត្តម លោកជំទាវបានលើកឡើងនោះ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាច និងមិនដែល ធ្វើអ្វីឱ្យហួសពីច្បាប់កំណត់ឱ្យធ្វើបានឡើយ ។

ដោយហេតុថា ពាក្យសុំបកស្រាយរបស់ឯកឧត្តម លោកជំទាវ មិនមែនជាពាក្យសុំបកស្រាយ រដ្ឋធម្មនុញ្ញសុទ្ធសាធទេនោះ ក្រុមប្រឹក្សាធម្មនុញ្ញ សូមបង្វិលពាក្យរបស់ឯកឧត្តម លោកជំទាវនេះ ត្រឡប់ ជូនទៅឯកឧត្តម លោកជំទាវវិញ ។

ប៊ិន ឈិន